# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Feb-2012, 09:14
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ:/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើធ្វើប្រតិកម្មតបនឹងការលំបាកជាច្រើនដែលបានលោតឡើងដោយសារអ៊ីមែលរបស់លោកស្រី LAMB ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២

---

ដាក់ដោយ៖

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោកមេធាវី គង់ សំអុន

លោកមេធាវី Arthur VERCKEN

លោកមេធាវី Jacques VERGES

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Clémence WITT

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

កញ្ញា Mathilde CHIFFERT
កញ្ញា អ៊ួច ស្រីផាត

**មេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីខាងការពារក្តីទាំងអស់**

## សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃព្រហស្បតិ៍ ទី២ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង ១០ និង៤៨នាទីព្រឹក លោកស្រី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ភាគីនានា តាមរយៈអ៊ីមែលចំនួន ២ ទំព័រ ដែលមានចំណងជើងថា *"Message to the parties in advance of tomorrow morning's informal TMM"*។

២. អ៊ីមែលនេះត្រូវបានសរសេរជាភាសាអង់គ្លេស ដោយមិនមានផ្តល់ការបកប្រែជាភាសាខ្មែរ និងបារាំងទេ។ ដើម្បីឲ្យយល់បាន ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មានបំណងតបទៅអ៊ីមែលនេះ ដូចខាងក្រោមនេះ។

៣. ជាដំបូង ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមជំទាស់តាមរបៀបជាទូទៅ ទៅនឹងអវត្តមាននៃការពិភាក្សាដេញដោលជាសាធារណៈ ទៅលើសំណួរដែលមិនមិនត្រឹមតែពាក់ព័ន្ធតែនឹងការរៀបចំផ្នែកបច្ចេកទេសនៃរឿងក្តីប៉ុណ្ណោះទេ តែក៏ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការគោរពដល់សិទ្ធិខាងការពារក្តីផងដែរ។

៤. ក្រុមមេធាវីការពារក្តីយល់ឃើញ និងស្នើសុំថា ចាប់ពីពេលនេះទៅ ឲ្យមានសវនាការជាសាធារណៈចំពោះការពិភាក្សាដេញដោលលើសំណួរទាំងនេះ និងមិនមែនចេញសេចក្តីសម្រេចតាមរយៈអ៊ីមែល ឬក៏អនុស្សរណៈ ដែលមិនមែនជាសេចក្តីសម្រេចតាមផ្លូវតុលាការបែបនេះទៀតនោះទេ។ ជាងនេះទៀត ក្រុមមេធាវីការពារក្តីសម្គាល់ឃើញថា ការដែលធ្វើជាអ៊ីមែល ឬអនុស្សរណៈតែមួយភាសាបែបនេះ អាចធ្វើឲ្យមេធាវីណាម្នាក់ ទាំងខាងជាតិ ឬអន្តរជាតិ អាចឃ្លាតពីរឿងនោះបាន។

៥. ក្នុងអ៊ីមែលថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ នេះ លោកស្រី Lamb បានប្រាប់អំពីគោលបំណងរបស់អង្គជំនុំជម្រះ ឲ្យមានកិច្ចពិភាក្សាចំនួនពីរ ស្តីអំពីឯកសារ ដែលគ្រោងធ្វើឡើងនៅរវាងថ្ងៃទី១៣ និង១៦ ខែកុម្ភៈ ឆ្នាំ២០១២ ។

៦. កិច្ចពិភាក្សាទីមួយត្រូវបានប្រកាសឡើង ដូចជាមកសន្និដ្ឋានលើដំណាក់កាលបរិបទប្រវត្តិសាស្ត្រនៃសវនាការតូចទីមួយនេះ។ វាដូចជាតុលាការ តាមរយៈលោកស្រី Lamb ស្នើឲ្យភាគីនានាធ្វើការជ្រើសរើសនូវឯកសារទាំងឡាយណាដែលខ្លួនយល់ថា សំខាន់ ពីក្នុងចំណោមឯកសារទាំងឡាយ ដែលត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ (ដែលវាហាក់ដូចជាឯកសារចំនួន ១៣៥ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ដែលមានលេខកូតតុលាការ E3)។

៧. នៅក្នុងពេលសវនាការ ក្រុមមេធាវីការពារក្ដីរបស់ លោក ខៀវ សំផន បានធ្វើការកត់សម្គាល់ជូនអង្គជំនុំជម្រះថា ដំណើរការអនុវត្តរបស់អង្គជំនុំជម្រះ ក្នុងការប្រមូលយកបញ្ជីនៃឯកសារចំនួន ១៣៥ ដែលមានចុះលេខកូត E3 នោះ មិនអាចទទួលយកបានឡើយ។ ពីព្រោះថា ដើម្បីទទួលបានបញ្ជីឯកសារនេះ ក្រុមមេធាវីការពារក្ដីត្រូវទាក់ទងទៅខាងអង្គភាពបណ្ណសារ ក៏ប៉ុន្តែបើគេធ្វើបច្ចុប្បន្នភាពបញ្ជីឯកសារ E3 នេះ ហើយជូនដំណឹងជាប្រចាំដល់ភាគីនានា នោះវានឹងមានប្រសិទ្ធភាពច្រើនជាង។

៨. ជាការបញ្ជាក់បន្ថែម ក្នុងអ៊ីមែលរបស់ខ្លួន លោកស្រី Lamb បានអះអាងថា ការពិភាក្សាដេញដោលនេះនឹងត្រូវធ្វើឡើង ដោយហេតុថា ឯកសារដែលបានចោទឡើងនេះ មានចំនួនដ៏ច្រើន និងដើម្បីផ្ដល់ឱកាសឲ្យភាគីនិមួយៗធ្វើការបង្ហាញនូវ "ឯកសារសំខាន់ៗ" ដែលជាការដែលអាចឲ្យសាធារណជនបានដឹងអំពីរឿងក្ដីនេះផងដែរ។

៩. ក្រុមមេធាវីការពារក្ដីសូមរំលឹកថា ឯកសារដែលត្រូវបានដាក់បង្ហាញសម្រាប់ដំណាក់កាលដំបូងនេះ មានតែចំនួន ១៣៥ ប៉ុណ្ណោះ។

១០. ដូច្នេះ ក្រុមមេធាវីការពារក្ដីចាត់ទុកថា ប្រយោជន៍បីដែលលោកស្រី Lamb បានលើកឡើងគឺជាលេសសម្រាប់បញ្ជាក់ពីមូលហេតុ ពាក់ព័ន្ធនឹងផ្នែកចុងក្រោយនៃសវនាការ គឺអ្វីដែលគេហៅថា ការផ្ដល់ឱកាសឲ្យជនជាប់ចោទ មានប្រតិកម្មតបទៅលើ "ឯកសារសំខាន់" នានាដែលគេប្រគល់ជូនពួកគាត់។

១១. សេចក្ដីកត់សម្គាល់របស់ក្រុមមេធាវីការពារក្ដី មានលក្ខណៈសមហេតុផល ព្រោះថា ផ្នែកនៃ "បរិបទប្រវត្តិសាស្ត្រ" នេះ មិនទាន់ចប់នៅឡើយ ដោយហេតុថា សាក្សី និងអ្នកជំនាញខ្លះ ត្រូវមកផ្ដល់សក្ខីកម្មលើប្រធានបទនេះទៀត។ ជាឧទាហរណ៍ TCW-797 និង TCE-038 ។

១២. ជាការច្បាស់ណាស់ដែលថា នៅក្នុងឱកាសដែលជនជាប់ចោទទាំងនោះបង្ហាញខ្លួនចំពោះមុខតុលាការ ដែលនឹងមិនប្រព្រឹត្តទៅនៅមុនសប្ដាហ៍ ពីថ្ងៃទី១៣ ដល់ទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារថ្មីៗអាចនឹងត្រូវភាគីនានា ឬចៅក្រម លើកយកមក ពោលគឺ ត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះ វាហាក់ដូចជាពិបាកក្នុងការចាត់ទុកថា ការពិភាក្សាដេញដោលទៅលើដំណាក់កាលនេះត្រូវបានបញ្ចប់។ អង្គជំនុំជម្រះនឹងធ្វើដូចម្ដេច នៅពេលបន្ទាប់ពីនោះ ? តើអង្គជំនុំជម្រះត្រូវរៀបចំឡើងវិញនូវការពិភាក្សាដេញដោលរបៀបដូចគ្នានេះ លើកទី ២ ទៅលើបរិបទប្រវត្តិសាស្ត្រឬទេ? តើអង្គជំនុំជម្រះនឹងធ្វើអ្វីបន្តទៅទៀតនេះ? អង្គជំនុំជម្រះនឹងរៀបចំជាថ្មីវិញនូវការពិភាក្សាដេញដោលទីពីរ ក្នុងលំដាប់ដូចគ្នាលើបរិបទប្រវត្តិសាស្ត្រ

ទៀតឬ? វាដូចជាមិនច្បាស់លាស់សោះ។

១៣. នីតិវិធីដែលលោកស្រី Lamb បានស្នើឡើង ក្នុងនាមតុលាការនេះ នឹងគ្រាន់តែតម្រូវឲ្យលោក ខៀវ សំផន ឆ្លើយទៅនឹងសំណួរដែលភាគីដ៏ទៃទៀត និងចៅក្រម អាចនឹងចោទសួរដល់គាត់ ប៉ុណ្ណោះ បើទោះជាលោក ខៀវ សំផន ខ្លួនគាត់បានបញ្ជាក់តាំងពីពេលចាប់ផ្ដើមសវនាការ ជំនុំជម្រះមកថា គាត់សូមរង់ចាំទាល់តែសហព្រះរាជអាជ្ញាបង្ហាញភស្តុតាងដាក់បន្ទុករបស់ខ្លួន ឲ្យអស់សិន ទើបគាត់ប្រហែលជាអាចនឹងឆ្លើយទៅនឹងសំណួររបស់ភាគីនានា និងតុលាការ បាន។

១៤. ជំហររបស់លោក ខៀវ សំផន នេះ វាស្របទៅនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់ ហើយអង្គជំនុំជម្រះក៏បានយល់ស្របតាមហើយដែរ។ ប៉ុន្តែ សំណើរបស់លោកស្រី Lamb បែរជាដាក់កាតព្វកិច្ចឲ្យជនជាប់ចោទឆ្លើយទៅនឹងសំណួរភ្លាមៗ ដោយមិនអាចធ្វើនៅពេល ក្រោយបានឡើយ។ ស្ថានភាពបែបនេះរំលោភលើសិទ្ធិការពារក្ដី ហើយក៏មិនត្រូវទៅតាម ស្តង់ដារនៃការកាត់ក្តីប្រកបដោយយុត្តិធម៌ ដូចដែលមានចែងក្នុងបញ្ញត្តិច្បាប់អនុវត្តនៅចំពោះ មុខ អ.វ.ត.ក ដែរ។

១៥. ជាសន្និដ្ឋាន វាដូចជាគ្រោះថ្នាក់ណាស់ដែលយល់ថា ដំណាក់កាលមួយនៃរឿងក្ដីត្រូវបានបញ្ចប់ ដោយរឿងក្ដីមួយនោះទើបតែនឹងត្រូវបានចាប់ផ្ដើមតែប៉ុណ្ណោះនោះ។

១៦. **<u>ទី២</u>** លោកស្រី Lamb បានប្រាប់នៅក្នុងអ៊ីម៉ែលរបស់គាត់ អំពីគោលបំណងរបស់អង្គជំនុំ ជម្រះ ក្នុងការបើកកិច្ចពិភាក្សាតទល់គ្នារវាងភាគីទាំងអស់ ក្នុងផ្នែកទី២ នៃសប្តាហ៍ថ្ងៃទី ១៣ ដល់ ១៦ កុម្ភៈ ២០១២ ទៅលើឯកសារចំនួន ១៦៣ ដែលយោងនៅក្នុងកំណត់ជើងទំព័រ កថាខណ្ឌនៃដីកាដំណោះស្រាយដែលតុលាការបានជ្រើសរើស និងកំណត់ថា សម្រាប់សវនា-ការដំណាក់កាលបន្ទាប់នៃរឿងក្តី៖ *"រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យ ទាក់ទងការងារ"*។

១៧. បើទោះជា ក្នុងចំណោមឯកសារ ១៦៣ នោះ មានឯកសារចំនួន ៤៣ ត្រូវបានយកមកសម្អាង ក្នុងកំណត់ជើងទំព័រនៃកថាខណ្ឌដែលពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្រ្តហើយក៏ដោយ ក៏កំណត់ ជើងទំព័រទាំងនោះ ពាក់ព័ន្ធត្រឹមតែទំព័រមួយចំនួននៃឯកសារយោងទាំងនោះ ហើយដូច្នេះ មាន តែផ្នែកទាំងនោះតែប៉ុណ្ណោះដែលត្រូវបានចាត់ទុកថា បានបង្ហាញ ហើយបានទទួលលេខកូដ E3។

១៨. ជាងនេះទៀត ក្រុមមេធាវីការពារក្តីសូមឲ្យកត់សម្គាល់ថា មកទល់ថ្ងៃនេះ កថាខណ្ឌនានានៅ

ក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹង *"វចនាសម្ព័ន្ធរដ្ឋបាល និងវចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ"* មិនទាន់ទាំងត្រូវបានអានក្នុងសវនាការផង។ លើសពីការដែលក្រុមមេធាវីការពារក្តីត្រូវបានជំទាស់ទៅនឹងរបៀបនៃការផ្តល់ឯកសារនេះ យើងពិបាកនឹងមើលឲ្យឃើញថា តាមគំនិតដែលថាត្រឹមត្រូវរបស់អង្គជំនុំជម្រះនេះ តើកិច្ចពិភាក្សាលើឯកសារដែលចងភ្ជាប់ទៅនឹងកថាខណ្ឌទាំងនេះអាចប្រព្រឹត្តទៅរួចបានយ៉ាងដូចម្តេច។

១៩. លើសពីនេះទៀត និងបើទោះជាចំនួនឯកសារដែលនឹងត្រូវយកមកពិនិត្យនៅក្នុងផ្នែកទី២ នៃសវនាការ ថ្ងៃទី១៣ ដល់ ១៦ កុម្ភៈ ២០១២ មានច្រើន ឬតិចក៏ដោយ ក្រុមមេធាវីការពារក្តីសូមរំលឹកដល់តុលាការថា កិច្ចដំណើរការដែលអង្គជំនុំជម្រះបានអនុវត្តនេះ អាចត្រូវ បកស្រាយថា ជាដំណាក់កាលទីមួយនៃការបង្វែរបន្ទុកនៃភស្តុតាង ដែលធម្មតាត្រូវធ្លាក់ទៅលើស្មារបស់សហព្រះរាជអាជ្ញានោះហើយ។ ត្រង់ចំណុចនេះ ឃ្លាបន្ទាប់របស់លោកស្រី Lamb បានសរសេរថា៖ *"This hearing therefore grants parties the opportunity to rebut this presomption by providing reasoned argument in relation to specified documents alleged not to meet the criteria contained in Internal Rule 87 3"* ។

២០. ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមធ្វើការគូសបញ្ជាក់ក្នុងដំណាក់កាលនេះថា "ការកំណត់ប្រភេទ" ដ៏សាមញ្ញនៃឯកសារ ស្របតាមវិធាន ៨៧-៣ ត្រូវបានចាត់ទុកថា ជាករណីពិសេសក្នុងក្របខណ្ឌនៃការជំនុំជម្រះក្តីដោយយុត្តិធម៌។ ក្រុមមេធាវីការពារក្តីមានបំណងបង្ហាញនូវទស្សនៈករណ៍នានា ដែលខ្លួនយល់ឃើញថាមានលក្ខណៈចាំបាច់ដល់ការពារក្តីរបស់ខ្លួន និងលើកឡើងនូវរាល់ឯកសារសមស្របនានា អាស្រ័យទៅលើសាក្សីដែលនឹងត្រូវកោះហៅឲ្យចូលមកក្នុងសវនាការ និងប្រធានបទនានាដែលនឹងត្រូវលើកមកពិភាក្សាក្នុងអំឡុងនៃសវនាការនោះ។

២១. ជាថ្មីម្តងទៀត ភាពធ្ងន់ធ្ងរនៃសេចក្តីសម្រេចដែលត្រូវបានធ្វើតាមមធ្យោបាយជាអ៊ីមែល និងជាអនុស្សរណៈ តម្រូវឲ្យមេធាវីការពារក្តីលោក ខៀវ សំផន ធ្វើការជំទាស់ ហើយទាមទារឲ្យមានការជជែកដេញដោលក្នុងសវនាការជាសាធារណៈ មុននឹងចេញសេចក្តីសម្រេចប្រភេទនេះចាប់ពីពេលនោះតទៅ។

## ហេតុដូច្នេះ

២២. មេធាវីការពារក្ដីលោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- ប្រកាស និងសម្រេចថា រាល់សេចក្ដីសម្រេចទាំងអស់ដែលពាក់ព័ន្ធនិងការជម្រះក្ដី ព្រមទាំងសវនាការ ត្រូវតែធ្វើជាកម្មវត្ថុនៃការដេញដោលជាសាធារណៈ

- ប្រកាស និងសម្រេចថា អ៊ីមែល និងអនុស្សរណៈទាំងឡាយ នឹងអាចប្រើប្រាស់តែចំពោះសំណួរទាំងឡាយ ដែលពាក់ព័ន្ធតែនឹងការរៀបចំប្រព្រឹត្តទៅមួយគត់ ដោយពុំប៉ះពាល់ទៅដល់ការគោរពសិទ្ធិការពារក្ដី និង សិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌នោះទេ

- ផ្ដល់នូវឯកសារបកប្រែអ៊ីមែល ព្រមទាំងអនុស្សរណៈទាំងឡាយដែលបានចេញ និងដែលនឹងត្រូវចេញដោយអង្គជំនុំជម្រះ នៅក្នុងភាសាប្រើប្រាស់ផ្លូវការរបស់មេធាវីការពារក្ដី

- ប្រកាស និងសម្រេចថា ការពិភាក្សាដេញដោលលើបរិបទប្រវត្តិសាស្ត្រមិនទាន់ត្រូវបានបញ្ចប់ និងមិនត្រូវបានបញ្ចប់នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឡើយ

- លើកការពិភាក្សាដេញដោលដែលបានប្រកាសរួចនេះ ទៅធ្វើនៅកាលបរិច្ឆេទក្រោយទៀត ដែលនឹងត្រូវកំណត់នាពេលក្រោយ ដរាបណាសាក្សី និងអ្នកជំនាញទាំងអស់ដែលពាក់ព័ន្ធនឹងផ្នែកនៃសវនាការនេះ នឹងបង្ហាញខ្លួនគ្រប់គ្នាអស់ហើយ

- ប្រកាស និងសម្រេចថា នឹងបើកឲ្យមានការដេញដោលចំពោះមុខនៅពេលដែលមានបង្ហាញឯកសារនីមួយៗក្នុងអំឡុងពេលនៃការជំនុំជម្រះ ហើយនៅក្នុងពេលបញ្ចប់ការជំនុំជម្រះនឹងមានការពិភាក្សាជាទូទៅមួយដើម្បីអនុញ្ញាតិឲ្យភាគី អាចបង្ហាញនូវឯកសារនានាដែលមិនអាចបង្ហាញឡើងនៅពេលដែលមានការពិភាក្សា ដេញដោលនោះ។

- បង្គាប់ឲ្យក្រឡាបញ្ជីធ្វើបច្ចុប្បន្នភាពនៃបញ្ជីឯកសារដែលមានលេខសម្គាល់ E3 ជាប្រចាំ ហើយជូនដំណឹង អំពីបញ្ជីឯកសារនោះដល់ភាគីនៅរៀងរាល់ថ្ងៃសវនាការ។

| | | | |
|---|---|---|---|
| | លោកមេធាវី គង់ សំអុន<br>លោកមេធាវី Arthur VERCKEN<br>លោកមេធាវី Jacques VERGÈS | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |